


# តើលោកអ្នកមានអារម្មណ៍សំណាងយ៉ាងណាដែរ?

ខាងក្រោមនេះគឺជាការពិតទាំងឡាយ អំពីការលេងល្បែងស៊ីសងនៅតាមម៉ាស៊ីនផ្ទុកឃើរ:

- ម៉ាស៊ីនផ្ទុកឃើរ ត្រូវបានគេរៀបចំដាក់កម្មវិធីពីខាងក្នុងដើម្បីឲ្យលោកអ្នកនឹងលេងចាញ់ ហើយម៉ាស៊ីននឹងលេងឈ្នះ។
- លោកអ្នកមានឱកាសតិចជាង១ដង ក្នុងចំណោមឱកាស១០លានដង ដើម្បីលេងឲ្យបានឈ្នះរង្វាន់ខ្ពស់ជាងគេ។
- គ្មានអ្វីដែលលោកអ្នកអាចធ្វើបានឡើយ ដើម្បីនឹងបង្កើនឱកាសរបស់លោកអ្នកឲ្យលេងឈ្នះម៉ាស៊ីនផ្ទុកឃើរ។
- ប្រសិនបើលោកអ្នកខិតខំសាកល្បងដើម្បីលេងឲ្យបានឈ្នះប្រាក់ដែលលោកអ្នកបានលេងចាញ់នោះមកវិញ លោកអ្នកទំនងជាលេងចាញ់ប្រាក់កាន់តែច្រើនឡើងថែមទៀត។
- កាលណាលោកអ្នកលេងល្បែងស៊ីសងកាន់តែច្រើនណាស់ នោះលោកអ្នកទំនងជាកើតមានបញ្ហាល្បែងស៊ីសងកាន់តែធ្ងន់ធ្ងរថែមទៀត។

*“វាអាចនឹងងាយស្រួលរកបានប្រាក់នៅក្នុងប្រទេសនេះ ក៏ប៉ុន្តែវាអាចនឹងងាយស្រួលលេងចាញ់ច្រើនផងដែរ។!”*

# របៀបទាក់ទងជាមួយ Gambler’s Help

ទូរស័ព្ទ Gambler’s Help លេខ 1800 858 858.

កិច្ចបំរើ Gambler’s Help តាមទូរស័ព្ទ ធ្វើការ២៤ម៉ោងក្នុង១ថ្ងៃ ៧ថ្ងៃក្នុង១អាទិត្យ។

- ពេលណាលោកអ្នកទូរស័ព្ទ លោកអ្នកអាចស្នើសុំអ្នកបកប្រែភាសាមួយរូប - ឥតគិតថ្លៃទេ។
- កិច្ចបំរើនេះគឺជាកិច្ចបំរើរក្សាទុកជាសម្ងាត់ ហើយ Gambler’s Help នឹងមិនពិភាក្សាអំពីបញ្ហារបស់លោកអ្នក ជាមួយនរណាទៀតឡើយ។
- លោកអ្នកអាចនិយាយទៅកាន់ Gambler’s Help តាមទូរស័ព្ទ ឬលោកអ្នកអាចធ្វើការណាត់ជួប ដើម្បីនិយាយទៅកាន់នរណាម្នាក់ មុខទល់នឹងមុខនៅក្នុងតំបន់របស់លោកអ្នក។

លោកអ្នកក៏អាចបើកមើលទៅគ្រង់វិបសាយបានដែរ: **www.problemgambling.vic.gov.au** ដើម្បីទទួលយកព័ត៌មានបន្ថែម។

gambler’s**help**
1800 858 858

problemgambling.vic.gov.au

ផលិតដោយ

multicultural gambler’s help program

**រូបថត និងពាក្យស្រង់នៅក្នុងសន្លឹកព័ត៌មាននេះ ទទួលបានពីសមាជិកនៃសហគមន៍ខ្មែរ ដែលគេមានកង្វល់អំពីឥទ្ធិពលនៃបញ្ហាល្បែងស៊ីសង។*

**Khmer**



# តើលោកអ្នកកំពុងលេងល្បែងស៊ីសងជាមួយនឹងអនាគតរបស់លោកអ្នកឬ?

## ព័ត៌មានសំរាប់សហគមន៍ខ្មែរអំពីបញ្ហាល្បែងស៊ីសង

gambler’s**help**
1800 858 858

problemgambling.vic.gov.au



*បញ្ហាល្បែងស៊ីសងអាចប៉ះពាល់ដល់មនុស្សគ្រប់វប្បធម៌។ ដោយសារការដឹងបានច្រើនអំពីបញ្ហាល្បែងស៊ីសង លោកអ្នកអាចការពារខ្លួនលោកអ្នក ឬអ្នកឯទៀតនៅក្នុងសហគមន៍របស់លោកអ្នក។*

## តើល្បែងស៊ីសងជាអ្វី?

មានសណ្ឋាននៃល្បែងស៊ីសងជាច្រើន។ សណ្ឋាននៃល្បែងស៊ីសងនៅក្នុងប្រពៃណីខ្មែរមានរួមទាំងការភ្នាល់មាន់ជល់គ្នា ឬការភ្នាក់ត្រីជល់គ្នា និងការលេងល្បែងបៀរ។

មានសណ្ឋាននៃល្បែងស៊ីសងជាច្រើនគឺស្របច្បាប់នៅក្នុងប្រទេសអូស្ត្រាលី។ ប្រជាជនលេងល្បែងស៊ីសងនៅតាមម៉ាស៊ីនផ្លែឈើរ បៀរល្បែងស៊ីសងនៅតាមកាស៊ីណូ និងព្រឹត្តិការណ៍កីឡាឯទៀត។

មានមនុស្សខ្លះលេងល្បែងស៊ីសងដើម្បីឲ្យបានសប្បាយ និងជាការកំសាន្ត អ្នកខ្លះទៀតលេងល្បែងស៊ីសងក្នុងគោលបំណងឲ្យបានឈ្នះ ដើម្បីយកប្រាក់ទៅបង់សងបំណុល ឬដើម្បីរកប្រាក់ឲ្យបានច្រើនក្នុងពេលយ៉ាងឆាប់។

មិនថាមកពីមូលហេតុអ្វីបានជាមនុស្សលេងល្បែងស៊ីសង ឬថាតើគេលេងល្បែងស៊ីសងជាមួយនឹងអ្វីទេ ការលេងល្បែងស៊ីសងអាចក្លាយទៅជាទម្លាប់មួយដ៏មានគ្រោះថ្នាក់ ហើយពិបាកនឹងបញ្ឈប់។

## តើលោកអ្នកមានបញ្ហាល្បែងស៊ីសងឬទេ?

១. តើលោកអ្នកបានលេងដាក់ភ្នាល់ប្រាក់ច្រើនជាងចំនួនប្រាក់ដែលលោកអ្នកអាចល្មមនឹងចាយវាយឬ?

២. តើលោកអ្នកត្រូវការលេងល្បែងស៊ីសងដោយដាក់ប្រាក់ច្រើន ដើម្បីឲ្យមានអារម្មណ៍រំភើបដូចគ្នាឬ?

៣. តើលោកអ្នកបានវិលត្រឡប់ទៅលេងក្នុងថ្ងៃមួយផ្សេងទៀតដើម្បីសាកល្បងលេងឲ្យបានឈ្នះប្រាក់ដែលលោកអ្នកបានលេងចាញ់ឬ?

៤. តើលោកអ្នកបានខ្ចីលុយ ឬលក់វត្ថុផ្សេងៗដើម្បីយកទៅលេងល្បែងស៊ីសងឬ?

៥. តើលោកអ្នកដែលមានអារម្មណ៍ថា លោកអ្នកមានបញ្ហាល្បែងស៊ីសងឬទេ?

៦. តើមានដែលគេរិះគន់ទៅលើការដាក់ភ្នាល់របស់លោកអ្នកឬទេ ឬបានប្រាប់លោកអ្នកថាលោកអ្នកប្រហែលជាមានបញ្ហាល្បែងស៊ីសងហើយ ទោះថាលោកអ្នកបានគិតថាវាពិត ឬមិនពិតនោះ?

៧. តើលោកអ្នកដែលមានអារម្មណ៍ថាបានធ្វើខុស ឬទេអំពីវិធីដែលលោកអ្នកលេងល្បែងស៊ីសង ឬអ្វីដែលកើតមានពេលណាលោកអ្នកលេងល្បែងស៊ីសង?

៨. តើល្បែងស៊ីសងបានបណ្តាលឲ្យលោកអ្នកមានបញ្ហាសុខភាពឬទេ មានរួមទាំងភាពតឹងតឹងចិត្ត ឬថប់អារម្មណ៍?

ប្រសិនបើលោកអ្នកឆ្លើយថា "បាទ / ចាស៎" ទៅនឹងសំណួរទាំងនេះណាមួយ នោះលោកអ្នកប្រហែលជាមានបញ្ហាល្បែងស៊ីសងហើយ។

មានផ្តល់ព័ត៌មានខាងវិជ្ជាជីវៈ ហើយរក្សាទុកជាសម្ងាត់ និងជំនួយសំរាប់លោកអ្នក។

*"ល្បែងស៊ីសងនឹងមិនគ្រាន់តែធ្វើឲ្យមានការរងទុក្ខដល់ហោប៉ៅរបស់លោកអ្នកប៉ុណ្ណោះទេ វាអាចធ្វើឲ្យរងទុក្ខដល់គ្រួសាររបស់លោកអ្នក មុខអាជីពរបស់លោកអ្នក ហើយនិងអនាគតរបស់លោកអ្នកផងដែរ។ "*

## តើលោកអ្នកអាចធ្វើអ្វីខ្លះ?

លោកអ្នកអាចទទួលយកឱវាទផ្នែកវិជ្ជាជីវៈ ហើយរក្សាទុកជាសម្ងាត់ ដើម្បីជួយលោកអ្នកទប់ទល់ ឬបញ្ឈប់ល្បែងស៊ីសងរបស់លោកអ្នក។

Gambler's Help (ជំនួយសំរាប់អ្នកលេងលែងស៊ីសង) គឺជាកិច្ចបំរើឥតគិតថ្លៃ សំរាប់ប្រជាជនដែលបានប៉ះពាល់ដោយសារបញ្ហាល្បែងស៊ីសង។

- លោកអ្នកអាចទូរស័ព្ទ Gambler's Help នៅពេលណាក៏បាន។
- លោកអ្នកអាចរកវិធីទាំងឡាយដើម្បីទប់ទល់ ឬបញ្ឈប់ល្បែងស៊ីសង។
- លោកអ្នកអាចនិយាយអំពីវិធីទាំងឡាយដើម្បីគ្រប់គ្រងថវិការបស់លោកអ្នក ហើយជំរះបំណុល។
- លោកអ្នកអាចទូរស័ព្ទ Gambler's Help ប្រសិនបើមាននរណាម្នាក់ដែលលោកអ្នកស្គាល់ មានបញ្ហាល្បែងស៊ីសង។
- លោកអ្នកអាចត្រូវគេដាក់ឲ្យទាក់ទងជាមួយ។

*មានមនុស្សជាច្រើនមកពីគ្រប់វប្បធម៌ បានដោះស្រាយបញ្ហាល្បែងស៊ីសងរបស់គេជាមួយកិច្ចបំរើ Gambler's Help។*

gambler'shelp
1800 858 858

problemgambling.vic.gov.au